**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្ដីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តកណ្ដាល មានភារកិច្ចរៀងៗខ្លួនអនុវត្តសេចក្ដី សំរេចនេះ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្ថលេខានិងត្រា ហត្ថលេខានិងត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

# ៣—សារាចរណែនាំ

ភ្នំពេញ,ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៦

**សារាចរណែនាំលេខ ០៤ ស.រ.ណ.ន**

## ស្ដីពីការកំណត់គោលការណ៍ការងារធារាសាស្ត្រ

ព្រះរាជាណាចក្រកម្ពុជា ពឹងផ្អែកទាំងស្រុងទៅលើវិស័យកសិកម្មក្នុងការងារនីតិសម្បទា និង កិច្ចអភិវឌ្ឍន៍ប្រទេសជាតិ ព្រោះប្រជាពលរដ្ឋជាង ៨០ % នៃប្រជាពលរដ្ឋទាំង អស់ជាប្រជាកសិករ ។ នៅគ្រប់សម័យកាលកសិកម្មនៅតែត្រូវបានចាត់ទុកជាវិស័យដ៏សំខាន់ នៃប្រទេសជាតិ ។ ជាក់ស្ដែងក្នុងបន្ទាត់ នយោបាយនៃរាជរដ្ឋាភិបាលកម្ពុជាបានកំណត់ច្បាស់ថា : កសិកម្មជាវិស័យអាទិភាព ដែលត្រូវគិតគូរយកចិត្តទុកដាក់អោយបានខ្លាំងក្លា ព្រោះជាបញ្ហាសំខាន់នៃស្ថេរភាពសង្គមក្នុងនេះ ការងារចំបងគឺ " បញ្ហា នយោបាយទឹក" ។

ឈរលើទស្សនៈខាងលើនេះ ការងារស្ដារ និង កសាងប្រព័ន្ធធារាសាស្ត្របាន និងកំពុងក្លាយជាចលនាមួយយ៉ាងផុសផុលពីសំណាក់រាជរដ្ឋាភិបាល អង្គការសង្គមអង្គការអន្តរជាតិអង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនឯកជន និង សប្បុរសជន ។ល។ ប៉ុន្តែទន្ទឹមនឹង

នេះរាជរដ្ឋាភិបាលបានសង្កេតឃើញថា ៖

– សំណង់ធារាសាស្ត្រមួយចំនួនបានអនុវត្តសមស្រប និង ត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេស រីឯមួយចំនួនទៀតពុំទាន់មានការគិតគូរខ្ពស់ដល់បញ្ហានេះនៅឡើយទេ ។

– មានភាពអនាធិបតេយ្យក្នុងការកសាងលំនៅដ្ឋាននៅលើសំណង់ទ្វារទឹក ខ្នងទំនប ប្រឡាយនាំទឹក ការចាប់ដីធ្លីនៅក្នុងអាងទឹក ការកាប់គាស់ប្រឡាយ–ទំនប់ ការលួចសំភារៈ និង បរិក្ខារសំណង់បញ្ចាទឹក ។ល។ និង ។ល។

ក្នុងគោលបំណងជំរុញដល់ការដាំដុះ ធានាបាននូវសន្តិសុខស្បៀង ទប់ស្កាត់បាននូវភាពអនាធិបតេយ្យ និង ភាពមហន្តរាយនានា ដែលអាចកើតមានឡើងជាយថាហេតុក្រោយពេលសាងសង់សំណង់ធារាសាស្ត្ររួចហើយ និង ក្នុងគោលបំណងថែទាំប្រព័ន្ធស្រោចស្រពអោយស្ថិតក្នុងល័ក្ខខ័ណ្ឌនៃការប្រើប្រាស់យូរអង្វែង ពង្រីកបាននូវសមត្ថភាពនៃការប្រើប្រាស់ និង សក្តានុពលនៃការស្រោចស្រព ព្រមទាំងកាត់បន្ថយបាននូវការចំណាយជាប្រចាំរបស់រាជរដ្ឋាភិបាលលើការងារថែទាំ និង ប្រើប្រាស់ប្រព័ន្ធធារាសាស្ត្ររាជរដ្ឋាភិបាលសូមធ្វើការណែនាំស្តីពីការកំណត់គោលការណ៍លើការងារធារាសាស្ត្រដូចតទៅ ៖

**I-អំពីការកំណត់ប្រភេទប្រព័ន្ធធារាសាស្ត្រ :**

១–ប្រភេទតូច : គឺប្រព័ន្ធធារាសាស្ត្រ ដែលមានលទ្ធភាពស្រោចស្រពលើផ្ទៃដីក្រោម ២០០ ហិកតា ។

២– ប្រភេទមធ្យម : គឺប្រព័ន្ធធារាសាស្ត្រ ដែលមានលទ្ធភាពស្រោចស្រពលើផ្ទៃដីពី ២០០ ហិកតា ទៅ ៥០០០ ហិកតា ។

៣– ប្រភេទធំ : គឺប្រព័ន្ធធារាសាស្ត្រ ដែលមានលទ្ធភាពស្រោចស្រព លើផ្ទៃដីលើសពី ៥០០០ ហិកតា និង មានផលប្រយោជន៍លើច្រើនវិស័យ ។

**II-អំពីគោលការណ៍នៃការអនុវត្តន៍ការងារ :**

១– ការងារសិក្សាគ្រោងប្លង់ : ចែកចេញជា ២ ផ្នែក ៖

ផ្នែកទី ១ : ការងារសិក្សាគ្រោងប្លង់ចំពោះមុខនោះគឺប្រភេទតូច ដែលជាការ

[illegible] និង មិនមានផលប៉ះពាល់ដល់ប្រព័ន្ធខ្នាតធំ ជាសមត្ថកិច្ចរបស់ការិយាល័យធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ ខេត្ត–ក្រុង តែចាំបាច់ត្រូវអនុវត្តទៅតាមបទដ្ឋានបច្ចេកទេសដោយឆ្លងតាមការត្រួតពិនិត្យពី អគ្គនាយកដ្ឋានធារាសាស្ត្រឧតុនិយម និងជលសាស្ត្រនិងរាយការណ៍ជាប្រចាំអំពីលទ្ធផលសំរេចបាន ។

ផ្នែកទី ២ : ការងារសិក្សាគ្រោងប្លង់ធារាសាស្ត្រ ប្រភេទមធ្យម និង ធំ ដែលទាមទាររយៈពេលយូរ ចំណាយថវិកាច្រើន និង មានការពាក់ព័ន្ធស្មុគស្មាញ ជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានធារាសាស្ត្រឧតុនិយម និង ជលសាស្ត្រទាំងស្រុង ។

២– ការងារជួសជុល និង សាងសង់ : ការងារនេះចែកជា ៤ ផ្នែក ÷

ផ្នែកទី ១ : ចំពោះសំណង់ធារាសាស្ត្រប្រភេទតូច ដែលម្ចាស់ការដោយប្រជាជនផ្ទាល់ការិយាល័យធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រខេត្ត–ក្រុង ជាអ្នកណែនាំបច្ចេកទេស ។

ផ្នែកទី ២ : សំណង់ធារាសាស្ត្រប្រភេទមធ្យមដែលរដ្ឋ និង ប្រជាជនរួមគ្នាធ្វើ អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រជាអ្នកទទួលខុសត្រូវលើការងារសិក្សាគ្រោងប្លង់វិការអនុវត្ត ត្រូវមានការចូលរួមពីសំណាក់ការិយា ល័យធារាសាស្ត្រឧតុនិយម និងជលសាស្ត្រខេត្ត–ក្រុង និងប្រជាជន ។

ផ្នែកទី ៣ : ចំពោះសំណង់ធារាសាស្ត្រប្រភេទមធ្យមប្រើប្រាស់ដោយថវិការដ្ឋ អគ្គនាយកដ្ឋាន ធារាសាស្ត្រឧតុនិយម និង ជលសាស្ត្រជាអ្នកទទួលខុសត្រូវទាំងស្រុង ។

ផ្នែកទី ៤ : ចំពោះសំណង់ធារាសាស្ត្រប្រភេទធំ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទជាអ្នកទទួលខុសត្រូវ និង ពិភាក្សាជាមួយបណ្តាក្រសួងមួយចំនួនទៀត ដែលមានការពាក់ព័ន្ធ ។

## III-អំពីការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ :

ការងារនេះចែកចេញជា ៤ ផ្នែក ÷

ផ្នែកទី ១ : ប្រព័ន្ធធារាសាស្ត្រប្រភេទតូច និងមធ្យមដែលស្ថិតក្នុងស្រុក–ខ័ណ្ឌតែមួយជាសមត្ថ កិច្ចរបស់ធារាសាស្ត្រស្រុក–ខ័ណ្ឌសាមី ។ ក្នុងករណីដែលប្រព័ន្ធធារាសាស្ត្រប្រភេទនេះមានការពាក់ព័ន្ធរវាងស្រុក–ខ័ណ្ឌ និង ស្រុក–ខ័ណ្ឌ ជាសមត្ថកិច្ចរបស់ការិយាល័យធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ ខេត្ត–ក្រុង ។

ផ្នែកទី ២ : ប្រព័ន្ធធារាសាស្ត្រប្រភេទតូច និង មធ្យមដែលស្ថិតក្នុងខេត្ត–ក្រុងតែមួយជាសមត្ថកិច្ចរបស់ការិយាល័យធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រខេត្ត–ក្រុង ។ ក្នុងករណីដែលប្រព័ន្ធ ធារាសាស្ត្រប្រភេទនេះមានការពាក់ព័ន្ធរវាងខេត្ត–ក្រុង និង ខេត្ត–ក្រុង ជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន ធារាសាស្ត្រឧតុនិយម និង ជលសាស្ត្រ ។

ផ្នែកទី ៣ : ប្រព័ន្ធធារាសាស្ត្រប្រភេទធំ ជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ ។

ផ្នែកទី ៤ : ចំពោះប្រព័ន្ធធារាសាស្ត្រ ដែលរដ្ឋបានប្រគល់ជូនអង្គភាព ក្រុមហ៊ុនឯកជន អង្គការសង្គមនានាគ្រប់គ្រង ការងារជួសជុលថែទាំជាបន្ទុករបស់សាមីខ្លួន ។

## IV-**អំពីការងារអន្តរាគមន៍ទប់ទល់នឹងគ្រោះទឹកជំនន់** :

នៅពេលមានគ្រោះទឹកជំនន់ ដែលបង្កអោយមានអន្តរាយដល់អាយុជីវិតមនុស្ស–សត្វ ទ្រព្យសម្បត្តិ ផលដំណាំរបស់ប្រជារាស្ត្រ អង្គភាពធារាសាស្ត្រ និង អាជ្ញាធរដែនដីត្រូវចាត់ការអន្តរាគមន៍ទប់ទល់ជាបន្ទាន់ និង រាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ "អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ" ដើម្បីមានវិធានការជាបន្ទាន់ ។

## V-**អំពីការងារអន្តរាគមន៍ទប់ទល់នឹងគ្រោះរាំងស្ងួត** :

ផ្នែកទី ១ : គ្រោះរាំងស្ងួតដែលកើតមានឡើងនៅក្នុងក្របខ័ណ្ឌ ឃុំ–សង្កាត់ភ្នាក់ងារធារាសាស្ត្រកសិកម្មស្រុក–ខ័ណ្ឌនិង អាជ្ញាធរដែនដីត្រូវចាត់ការអន្តរាគមន៍ទៅតាមលទ្ធភាពជាក់ស្តែង និង រាយការណ៍ ទៅការិយាល័យធារាសាស្ត្រឧតុនិយម និង ជលសាស្ត្រខេត្ត–ក្រុងរៀងខ្លួនជាបន្ទាន់ ។

ផ្នែកទី ២ : គ្រោះរាំងស្ងួតដែលកើតមានឡើងនៅក្នុងក្របខ័ណ្ឌខេត្ត–ក្រុង ការិយាល័យធារាសាស្ត្រ និង អាជ្ញាធរដែនដីត្រូវចាត់ការអន្តរាគមន៍ទៅតាមលទ្ធភាពជាក់ស្តែង និង រាយការណ៍ទៅអគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយមនិងជលសាស្ត្រជាបន្ទាន់ ។

ផ្នែកទី ៣ : គ្រោះរាំងស្ងួតដែលកើតមានឡើងនៅក្នុងក្របខ័ណ្ឌទូទាំងប្រទេសជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានធារាសាស្ត្រឧតុនិយមនិងជលសាស្ត្រ ។

## VI-ការកំណត់ទីតាំងសំណង់ប្រព័ន្ធធារាសាស្ត្រ :

រាល់ការសាងសង់ប្រព័ន្ធធារាសាស្ត្រ ត្រូវមានការគិតគូរខ្ពស់ដល់ការងារការពារបរិស្ថានប្រព័ន្ធជីវសាស្ត្រចំរុះ និង ដែននេសាទ ។

## VII-គោលនយោបាយរបស់រាជរដ្ឋាភិបាល :

១–<u>អំពីប្រេងបូមទឹកប្រឡាយមេ</u> :

រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយប្រឡាយមេ ដោយប្រគល់ភារកិច្ចអោយអគ្គនាយកដ្ឋានធារាសាស្ត្រឧតុនិយម និង ជលសាស្ត្រ នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទទទួលបន្ទុកអនុវត្តការងារនេះ ។

២–<u>ការងាររៀបចំសមាគមកសិករប្រើប្រាស់ទឹក</u> :

អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយមជលសាស្ត្រ នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ មានភារកិច្ចណែនាំរៀបចំចងក្រងត្រួតពិនិត្យនូវរាល់សមាគមប្រើប្រាស់ទឹកដើម្បីធានាការគ្រប់គ្រង និង ប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដោយភាពម្ចាស់ការ និង មានប្រសិទ្ធភាពខ្ពស់ ។

៣–<u>អំពីការងារស្តារ និង កសាងប្រព័ន្ធធារាសាស្ត្រ</u> :

រាជរដ្ឋាភិបាលមានគោលនយោបាយលើកទឹកចិត្តដល់ក្រុមហ៊ុនឯកជន អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ឬបុគ្គលដែលបានបណ្តាក់ទុនលើការស្តារ និង កសាងប្រព័ន្ធធារាសាស្ត្រ តែត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យពីអគ្គនាយកដ្ឋានធារាសាស្ត្រឧតុនិយម និង ជលសាស្ត្រនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ។

៤–<u>អំពីការរៀបចំរបៀបរបបដាំដុះ</u> :

ចំពោះតំបន់ដែលផលិតស្រូវឡើងទឹក គប្បីពិនិត្យលទ្ធភាពបង្វែរទៅធ្វើស្រូវស្រាលជំនួសវិញ ដោយផ្តល់អាទិភាពខ្ពស់លើការស្តារ និង រៀបចំប្រព័ន្ធធារាសាស្ត្រមធ្យម និងតូច នៅតំបន់នេះ និង នៅតំបន់ប្រពលវប្បកម្ម និង បង្កើនរដូវ ដើម្បីជំរុញទិន្នផលទ្វេរឡើង ។

រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងកក់ក្ដៅបំផុត ចំពោះគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ខេត្ត ក្រុង អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិនានា នឹងលើកកំពស់ឆន្ទៈ អនុវត្តសារាចរណែនាំនេះអោយបានជោគជ័យ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

* * *

## II ការងារបណ្ដាក្រសួង

### ១—ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ១១៩ សហវ. ប្រក. ប**

**ស្ដីពីការទទួលស្គាល់បុគ្គលិកអតីតរចនាសម្ព័ន្ធ**

**របស់គាត់ រ.ជ.រ.ប.ខ ចំនួន ១០៨ នាក់ និង**

**អ្នកបច្ចេកទេសដែលទើបបញ្ចប់ការសិក្សាពីក្នុង**

**និងក្រៅប្រទេស ចំនួន ៨៥ នាក់ អោយមកបំរើ**

**ការងារក្នុងក្របខ័ណ្ឌក្រសួង**

* * *

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

– បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញ ព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង